ATASK គឺជាភ្នាក់ងារប្រឆាំងអំពើហិង្សាក្នុងគ្រួសារសម្រាប់ជនរងគ្រោះជាតិសាសន៍អាស៊ី និងអ្នករួចផុតពីគ្រោះថ្នាក់នៅ ញូ អ៊ីងឡែន ដោយបម្រើអតិថិជនជាភាសាអាស៊ីចំនួន 14 ភាសា។ បេសកកម្មរបស់យើងគឺដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារក្នុងចំណោមគ្រួសារ និងសហគមន៍អាស៊ី និងដើម្បីផ្តល់ក្តីសង្ឃឹមដល់អ្នករួចផុតពីគ្រោះថ្នាក់។

**បូស្តុន៖**
ប្រអប់សំបុត្រលេខ 120108
Boston, MA 02112
ទូរសព្ទ៖ (617) 338-2350
ទូរសារ៖ (617) 338-2354

**ឡូវែល៖**
ប្រអប់សំបុត្រលេខ 7259
Lowell, MA 01853
ទូរសព្ទ៖ (978) 454-3651
ទូរសារ៖ (978) 937-2355

## ខ្សែទូរសព្ទជំនួយទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ពហុភាសា 24 ម៉ោង

# (617) 338-2355

- បាំងក្លា
- វៀតណាម
- ចិនកាតាំង
- តៃវ៉ាន់
- ឥណ្ឌូណេស៊ី
- ហិណ្ឌី
- នេប៉ាល់
- អ៊ូឌូ
- ថៃ
- កាតាឡុក (ហ្វីលីពីន)
- ចិនកុកងឺ មៀន
- ខ្មែរ (កម្ពុជា)
- ជប៉ុន
- កូរ៉េ
- ម៉ានីពូរី

*គម្រោងនេះត្រូវបានគាំទ្រដោយជំនួយរដ្ឋាភិបាលលេខ 2014-WL-AX-0036 ដែលផ្តល់ដោយការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ មតិ លទ្ធផលរកឃើញ សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា ដែលបានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយ/កម្មវិធី/ពិព័រណ៍នេះគឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងយុត្តិធម៌ ការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនោះទេ។

សំណួរសួរញឹកញាប់ ដែលសរសេរដោយកម្មវិធីតស៊ូមតិផ្នែកច្បាប់ ATASK។ កំណែចុងក្រោយ ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2016

**ASIAN TASK FORCE**
Against Domestic Violence

# ការការពារផ្នែកច្បាប់ពីការបំពាន សំណួរដែលសួរញឹកញាប់

## កម្មវិធីតស៊ូមតិផ្នែកច្បាប់

ខ្សែទូរសព្ទជំនួយពហុភាសា 24 ម៉ោង
**(617) 338-2355**

www.atask.org

**ASIAN TASK FORCE**
Against Domestic Violence

# កម្មវិធីតស៊ូមតិផ្នែកច្បាប់

កម្មវិធីតស៊ូមតិផ្នែកច្បាប់របស់យើងខិតខំបំពេញចន្លោះខ្វះខាតសំខាន់ៗនៅក្នុងការផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងការប្រទូស្តកេរ្តិ៍ភេទនៃមរតកអាស៊ី ឬអាមេរិកអាស៊ី។

ចាប់តាំងពីពេលបង្កើតឡើងនៅឆ្នាំ 2009 យើងបានផ្តល់សេវាតស៊ូមតិ ភាពជាតំណាង និងការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់អតិថិជនរបស់ ATASK ដើម្បីជួយធានាសិទ្ធិស្របច្បាប់របស់ពួកគាត់ក្នុងការក្លាយជាបុគ្គលឯករាជ្យ និងមានសុវត្ថិភាព រួចផុតពីការប្រើអំណាច និងការគ្រប់គ្រងរបស់ជនបំពាន។

ប្រវត្តិសហការរបស់យើងជាមួយអង្គការតាមសហគមន៍ សាលានីតិសាស្ត្រ សេវាផ្នែកច្បាប់ និងមេធាវីជួយជនក្រីក្រ មានន័យថា យើងធ្វើការយ៉ាងហ្មត់ចត់ ដើម្បីធានាថា អ្នករួចផុតពីគ្រោះថ្នាក់មិនត្រូវបានបដិសេធក្នុងការទទួលបានភាពជាតំណាងផ្នែកច្បាប់ ជំនួយយុទ្ធសាស្ត្រ ការណែនាំ ឬការបញ្ជូនដោយជោគជ័យ។

ការបដិសេធទទួលខុសត្រូវ៖ ខ្លឹមសារក្នុងទំព័រនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាការផ្តល់ប្រឹក្សាផ្នែកច្បាប់នោះទេ។ មុននឹងអ្នកសម្រេចធ្វើសកម្មភាពណាមួយ ATASK លើកទឹកចិត្តឱ្យអ្នកស្វែងរកការប្រឹក្សាយោបល់ពីមេធាវីនៅរដ្ឋម៉ាសាឈូសេតស៍ ដើម្បីជួយអ្នកវិភាគលើស្ថានភាពពិសេស និងជាក់លាក់របស់អ្នក ដើម្បីស្វែងរកដំណោះស្រាយល្អបំផុត ដែលស្របតាមតម្រូវការរបស់អ្នក។

# ត្រូវការជំនួយបន្ថែមមែនទេ?

ក្នុងករណីបន្ទាន់ សូមទូរសព្ទទៅកាន់ 911

Safelink ....................1-877-785-2020
....................1-877-521-2601

Greater Boston Legal Services ....................617-371-1234
....................800-323-3205

Legal Advocacy and Resource Center, Inc....................617-603-1700
....................800-345-5297

Metro West Legal Services ....................508-620-1830
....................800-696-1501

Northeast Legal Aid ....................978-458-1465
....................800-336-2262

National Lawyers Guild ....................617-227-7008

Boston Bar Association Lawyer Referral Service ...617-742-0625
....................800-552-7046

Massachusetts Bar Association ....................617-654-0400
....................866-627-7577

## ចុះបើខ្ញុំមិនមានទំនាក់ទំនងក្នុងគ្រួសារជាមួយអ្នកបំពានលើខ្ញុំ ប៉ុន្តែខ្ញុំរងការបំពាន ឬការគំរាមកំហែងពីគាត់ម្តងហើយម្តងទៀតវិញ?

អ្នកអាចនឹងទទួលបានដីកាទប់ស្កាត់ការបៀតបៀន 258E ដើម្បីទប់ស្កាត់ការបៀតបៀនតទៅទៀត។

**ដើម្បីទទួលបានដីកាទប់ស្កាត់ការបៀតបៀន 258E អ្នកបៀតបៀនអ្នកត្រូវធ្លាប់ធ្វើអំពើណាមួយដូចខាងក្រោម៖**

1) បានប្រព្រឹត្តអំពើដោយចេតនា និងលក្ខណៈព្យាបាទបីដងមកលើអ្នក ដែលមានបំណង និងបានបណ្តាលឱ្យមានការភ័យខ្លាច ការបំភិតបំភៃ ការបំពាន ឬការបំផ្លាញទ្រព្យសម្បត្តិ

2) បានបង្ខំឱ្យអ្នកមានទំនាក់ទំនងផ្លូវភេទ

**ឬ**

3) បានប្រព្រឹត្តបទល្មើសមួយចំនួនដូចជា បទល្មើសឈ្លបចាប់រំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ ឬការបង្ករបួសស្នាមលើកុមារ។

ដីកាទប់ស្កាត់ការបៀតបៀនអាចតម្រូវឱ្យអ្នកបៀតបៀនអ្នកឈប់បៀតបៀន និងបំពានអ្នក ឈប់ទាក់ទងមកអ្នក នៅឱ្យឆ្ងាយពីផ្ទះ ឬកន្លែងធ្វើការរបស់អ្នក ហើយក្នុងករណីខ្លះ បង់ការខូចខាតជាប្រាក់ដល់អ្នក។ ការប្រព្រឹត្តខុសពីដីកានេះគឺជាបទល្មើសមួយ។

អ្នកមិនចាំបាច់មានទំនាក់ទំនងណាមួយក្នុងផ្ទះ គ្រួសារ ឬស្នេហាជាមួយអ្នកបំពានលើអ្នកនោះទេ។ អ្នកអាចប្រើដីកានេះ ដើម្បីការពារអ្នកពីនិយោជក សហសេវិក មិត្តភក្តិ អ្នកស្គាល់គ្នា ជនប្លែកមុខ ។ល។

សម្រាប់ព័ត៌មានបន្ថែមអំពីដីកាទប់ស្កាត់ការបៀតបៀន 258E **សូមមើលកូនសៀវភៅស្តីពីដីកាហាមឃាត់។**

ប្រភព៖ M.G.L.A. 258E.

## តើអ្វីខ្លះដែលត្រូវបានចាត់ទុកថាជាការបំពានក្រោមច្បាប់ទប់ស្កាត់ការ

ប្រសិនបើដៃគូរបស់អ្នក សមាជិកគ្រួសារណាមួយដែលជាប់សាច់ឈាម ឬជាសាច់ថ្លៃរបស់អ្នក ឬអ្នកដែលអ្នករស់នៅជាមួយវាយអ្នក គំរាមកំហែងវាយអ្នក បង្ខំអ្នកឱ្យរួមភេទដែលផ្ទុយពីឆន្ទៈរបស់អ្នក និងធ្វើឱ្យអ្នកភ័យខ្លាចពួកគាត់ផ្នែករាងកាយ អ្នកកំពុងរងការបំពានហើយ ហើយអ្នកអាចស្វែងរកការការពារផ្នែកច្បាប់ពីតុលាការរដ្ឋម៉ាសាឈូសេតស៍។

## ប្រសិនបើខ្ញុំកំពុងរងការបំពាន ឬធ្លាប់រងការបំពាននាពេលថ្មីៗនេះ តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីការពារខ្លួនឯងដោយស្របច្បាប់បាន?

អ្នកអាចទូរសព្ទទៅនគរបាល រួចស្នើពួកគាត់ឱ្យ៖

- មកន្លែងដែលអ្នកកំពុងនៅ
- បញ្ឈប់ការបំពាន ជួយអ្នកដោយផ្តល់ថ្នាំតាមតម្រូវការរបស់អ្នក និង
- រាយការណ៍អំពីហេតុការណ៍បំពានជាផ្លូវការ។ នគរបាលក៏អាចចាប់ខ្លួនអ្នកបំពានលើអ្នកផងដែរ។

អ្នកក៏អាចស្វែងរកជំនួយក្នុងតុលាការផងដែរ៖

- អ្នកអាចដាក់បណ្តឹងព្រហ្មទណ្ឌ
- ហើយ/ឬអ្នកអាចស្វែងរកដីកាការពារ (ឬហៅម្យ៉ាងទៀតថាដីកាហាមឃាត់ 209A) ដែលតម្រូវឱ្យប្តី/ប្រពន្ធ ឬដៃគូរបស់អ្នកនៅឱ្យឆ្ងាយពីអ្នក។

ប្រភព៖ M.G.L.A. 209A § 6

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំទូរសព្ទទៅនគរបាល នៅពេលខ្ញុំរងការបំពាន?

**ប្រសិនបើភាសាអង់គ្លេសរបស់អ្នកមានកម្រិត អ្នកមានសិទ្ធិស្នើសុំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ពីនគរបាលបាន។**

នគរបាលត្រូវមកកន្លែងដែលអ្នកកំពុងនៅ ហើយជួយការពារអ្នក ដោយមិនគិតពីឋានៈអន្តោរប្រវេសន៍របស់អ្នកនោះទេ។ ពួកគាត់នឹងសម្ភាសអ្នក និងដៃគូរបស់អ្នកអំពីអ្វីដែលបានកើតឡើង។ ពួកគាត់នឹងសរសេរកំណត់ហេតុផ្លូវការមួយ ផ្អែកលើការសម្ភាសទាំងនេះ និងការអង្កេតរបស់ពួកគាត់ ដែលអាចត្រូវបានប្រើប្រាស់នៅពេលក្រោយនៅក្នុងតុលាការ។ អ្នកមានសិទ្ធិក្នុងការទទួលបានច្បាប់ចម្លងនៃកំណត់ហេតុនេះដោយឥតគិតថ្លៃ។

នគរបាលអាចនៅជាមួយអ្នក រហូតទាល់តែអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព។ បើចាំបាច់ ពួកគាត់អាចយកអ្នកទៅមន្ទីរពេទ្យ ឬជម្រកមួយ។ ពួកគាត់ក៏អាចជួយអ្នកឱ្យទទួលបានដីការហាមឃាត់បន្ទាន់ប្រឆាំងនឹងអ្នកបំពានលើអ្នក។

ប្រសិនបើពួកគាត់ជឿថា ការបំពានបានកើតឡើង ពួកគាត់អាចចាប់ខ្លួនអ្នកបំពានបាន។ ប្រសិនបើនគរបាលសម្រេចមិនចាប់ខ្លួន ហើយអ្នកភ័យខ្លាចពីសុវត្ថិភាពរបស់អ្នក ចូរស្នើឱ្យនគរបាលនាំអ្នកទៅជម្រកមួយ។ សម្រាប់ព័ត៌មានអំពីជម្រកបណ្ដោះអាសន្ន និងពាក់កណ្ដាលអចិន្ត្រៃយ៍ **ចូរមើលកូនសៀវភៅអំពីលំនៅដ្ឋាន**។

ប្រភព៖ M.G.L.A. 209A § 6

## តើខ្ញុំអាចធ្វើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមកលើប្ដី ឬដៃគូរបស់ខ្ញុំដែលបានបំពានខ្ញុំដែរឬទេ?

មានតែមេធាវីរដ្ឋាភិបាលតែប៉ុណ្ណោះទើបអាចធ្វើការចោទប្រកាន់ខាងបទព្រហ្មពណ្ឌមកលើអ្នកបំពានលើអ្នកបាន។ ក្នុងនាមជាជនរងគ្រោះ អ្នកគឺជាសាក្សីម្នាក់។ រដ្ឋាភិបាលអាចចោទប្រកាន់អ្នកបំពានពីបទវាយប្រហារ ឬការបំពាន និងធ្វើបាប ឬបទល្មើសខាងព្រហ្មទណ្ឌដែលពាក់ព័ន្ធណាមួយ។

អ្នកអាចស្នើឱ្យរដ្ឋាភិបាលធ្វើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមកលើអ្នកបំពានលើអ្នក ដោយដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅតុលាការព្រហ្មទណ្ឌ។ អ្នកមិនអាចធ្វើការចោទប្រកាន់ និងដកការចោទប្រកាន់បានទេ។

## តើខ្ញុំត្រូវធ្វើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមកលើអ្នកបំពានខ្ញុំដែរឬទេ? តើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌនឹងមានឥទ្ធពលអ្វីខ្លះ?

ប្រសិនបើរដ្ឋាភិបាលសម្រេចដាក់ទោសអ្នកបំពានលើអ្នក សក្ខីកម្មរបស់អ្នកជាសាក្សី ជាញឹកញាប់មានសារៈសំខាន់ខ្លាំងណាសម្រាប់ជោគជ័យរបស់ពួកគេ។ ប្រសិនបើអ្នកសម្រេចមិនធ្វើសក្ខីកម្មទេ រដ្ឋាភិបាលនឹងសម្រេចថាតើនឹងបន្តការចោទប្រកាន់ដោយគ្មានអ្នកឬយ៉ាងណា។ នៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ដែលសក្ខីកម្មរបស់អ្នកជាភស្តុតាងតែមួយគត់ រដ្ឋាភិបាលនឹងទំនងជាបញ្ចប់រឿងក្ដី។

រដ្ឋាភិបាលអាចធ្វើការចោទប្រកាន់បាន ទោះបីជាអ្នកមិនដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌក៏ដោយ។ ប្រសិនបើនគរបាលមកកាន់ផ្ទះរបស់អ្នក ហើយឃើញភស្តុតាងនៃការបំពាន នគរបាល ឬរដ្ឋអាជ្ញាក៏អាចដាក់បណ្ដឹងព្រហ្មទណ្ឌ ហើយរដ្ឋាភិបាលអាចសម្រេចថាតើដាក់ទោសដែរឬទេដោយផ្អែកទាំងស្រុងលើបណ្ដឹងទាំងនេះ។

## ចុះបើមិនមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌទេ ប៉ុន្តែខ្ញុំចង់ឱ្យប្ដី/ប្រពន្ធ ឬដៃគូរបស់ខ្ញុំឈប់បំពានខ្ញុំ?

អ្នកអាចដាក់ពាក្យសុំដីកាហាមឃាត់ការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ 209A ដែលជាដីកាទប់ស្កាត់ការបំពាន។

ដីកាហាមឃាត់ 209A អាចប្រាប់អ្នកបំពានលើអ្នកឱ្យឈប់បំពានលើអ្នកបាន (ទោះបីជាអ្នកបន្តរស់នៅជាមួយគាត់ក៏ដោយ) ឈប់ទាក់ទងមកអ្នក នៅឱ្យឆ្ងាយពីផ្ទះ ឬកន្លែងការងាររបស់អ្នក និង/ឬផ្លាស់ចេញ ប្រសិនបើអ្នកកំពុងរស់នៅជាមួយអ្នកបំពានលើអ្នក។ វាក៏អាចផ្ដល់សិទ្ធិចិញ្ចឹមកូនរបស់អ្នកជាបណ្ដោះអាសន្ន និងការជួយចិញ្ចឹមកូន ប្រសិនបើអ្នកបំពានលើអ្នកជាឪពុករបស់កូនអ្នក។

209A ការពារអ្នកដោយមិនចោទប្រកាន់អ្នកបំពានលើអ្នកពីបទល្មើសណាមួយឡើយ។ ទោះជាយ៉ាងណា អ្នកបំពាន**ត្រូវ**អនុវត្តតាមដីកានេះ។ ប្រសិនបើគាត់បំពានដីកានេះ នោះ ត្រូវ ចាត់ទុកថាជាបទល្មើសមួយ ហើយគាត់អាចត្រូវចាប់ខ្លួន។

**ដើម្បីទទួលបានដីកាការពារ អ្នកត្រូវបំពានតាមលក្ខខណ្ឌដូចខាងក្រោម៖**

1) អ្នក និងអ្នកបំពានរបស់អ្នកមាន/ធ្លាប់មានទំនាក់ទំនងជិតស្និទ្ធ រស់នៅ ឬធ្លាប់រស់នៅផ្ទះតែមួយ ឬជាប់ទាក់ទងគ្នាតាមរយៈអាពាហ៍ពិពាហ៍ ឬជាប់សាច់ឈាមគ្នា

2) គាត់បានគំរាមកំហែង ឬបានប៉ុនប៉ងគំរាមកំហែងបង្កគ្រោះថ្នាក់ *លើរាងកាយរបស់អ្នក* ឬបានបង្កគ្រោះថ្នាក់ *លើរាងកាយរបស់អ្នក។*

**ហើយ**

3) អ្នកខ្លាចថា អ្នកបំពានលើអ្នកនឹងបង្កគ្រោះថ្នាក់លើរាងកាយរបស់អ្នកម្ដងទៀតក្នុងពេលឆាប់ៗ។

អ្នកបំពានរបស់អ្នកអាចជាប្ដី/ប្រពន្ធបច្ចុប្បន្ន ឬពីមុន ដៃគូស្នេហាបច្ចុប្បន្ន ឬពីមុន អ្នករស់នៅផ្ទះ ឬបន្ទប់ជាមួយគ្នា ឬសាច់ញាតិ ដែលជាប់ទាក់ទងនឹងអ្នក តាមរយៈអាពាហ៍ពិពាហ៍ ឬជាប់សាច់ឈាមគ្នា។

សម្រាប់ព័ត៌មានស្ដីពីរបៀបដាក់ពាក្យស្នើសុំដីកាហាមឃាត់ និងអ្វីកើតឡើងនៅពេលអ្នកបំពានលើអ្នកប្រព្រឹត្តខុសពីដីកានេះ **សូមមើលកូនសៀវភៅស្ដីពីដីកាហាមឃាត់។**

ប្រភព៖ M.G.L.A. 209A